# ខ្លឹមសារសង្ខេប

ការបកស្រាយពាក្យ ការវាយប្រហារលើប្រជាជនស៊ីវិល ក្នុងបរិបទ នៃ
បទឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ (សហចៅក្រមស៊ើបអង្កេត សំណុំរឿង ០០៣ ឯកសារ D191/18
ចុះថ្ងៃទី ៧ ខែកុម្ភៈ ឆ្នាំ ២០១៧)

១. បរិបទនៃ ឧក្រិដ្ឋកម្មប្រព្រឹត្តដោយមេដឹកនាំខ្មែរក្រហម ក្នុងអំឡុងឆ្នាំ ១៩៧៥ ដល់ ១៩៧៩ មានភាពខុសគ្នាខ្លះពីអ្វីកើតនៅអន្តរជាតិ ដូចជា អំពើប្រល័យពូជសាសន៍ក្នុងប្រទេស រ្វាន់ដា។ នោះគឺការសម្លាប់ទាហានខ្លួនឯង ដែលចោទថាក្បត់នឹងអង្គការ។ វានាំឲ្យមានសំណួរផ្លូវច្បាប់ចោទឡើង ពាក់ព័ន្ធនឹងបទឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ៖ ថាតើការវាយប្រហារលើកងកម្លាំងទ័ពរបស់ខ្លួន ជាការវាយប្រហារលើជនស៊ីវិល?។ ដោយសារមានភាពមន្ទិលនេះ ហើយបញ្ហាច្បាប់នេះស្មុគ្រស្មាញ និងជាការអនុវត្តក្នុងច្បាប់ព្រហ្មទណ្ឌអន្តរជាតិ សហចៅក្រមស៊ើបអង្កេត បានប្រើសិទ្ធិស្នើឲ្យមិត្តរបស់តុលាការ បញ្ចេញយោបល់លើបញ្ហានេះ ជាលាយលក្ខអក្សរក្នុងទម្រង់ជា Amicus Curiae។ ជាលទ្ធផលមានការឆ្លើយតបចំនួន ១១ http://www.measboralaws.com/detail/1081 រួមជាមួយនឹងឯកសារអន្តរាគមន៍របស់ភាគីក្នុងសំណុំរឿង ដូច ជា មាស មុត http://www.measboralaws.com/detail/1080 ។

២. ក្រោយពីពិគ្រោះឯកសារ និងថ្លឹងថ្លែង ចៅក្រមយល់ឃើញថា៖ ការវាយប្រហារនេះ ចាត់ចូលជាការវាយប្រហារលើជនស៊ីវិល (កថាខ័ណ្ឌទី៥៥)។ នេះផ្អែកលើមូលដ្ឋាន៖ ក. កងកម្លាំងនៃប្រទេសខ្លួនមិនចូលក្នុងវិសាលភាពការពារដោយបទឧក្រិដ្ឋកម្មសង្គ្រាមទេ។ ខ. បទឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ចែងដាក់ទោសទណ្ឌនៃការបំពានសិទ្ធិមនុស្សធ្ងន់ធ្ងរ ជាប្រព័ន្ធ ទោះបីជាជនរងគ្រោះ ជាប្រជាជនរបស់ខ្លួនក្តី (humanity) ( កថាខ័ណ្ឌទី២៣)។ វាពាក់ព័ន្ធនឹងទ្រឹស្តីនៃការការពារសិទ្ធិមនុស្ស។ អ្វីសំខាន់ គឺក្នុងគោលបំណង ការពារជនរងគ្រោះ ដែលជាចម្បងជាជនស៊ីវិល។ ការបកស្រាយចង្អៀតនៃពាក្យ “ជនស៊ីវិល” តាមច្បាប់មនុស្សធម៌អន្តរជាតិ មិនត្រឹមត្រូវទេ។ អាស្រ័យហេតុនេះ ការបកស្រាយពាក្យនេះត្រូវមានលក្ខណៈទូលាយ (កថាខ័ណ្ឌទី៥៥)។ ការបកស្រាយនេះ សមស្របតាមគោលបំណងនៃសន្ធិសញ្ញា និងតាមវិធីបកស្រាយចែងក្នុងអនុសញ្ញា ស្តីពីច្បាប់សន្ធិសញ្ញាឆ្នាំ ១៩៦៩។

៣. ដើម្បីការពារគំហើញ សហចៅក្រមស៊ើបអង្កេត បានអះអាងបន្ថែមថា ការបកស្រាយនេះ មិនប៉ះដល់គោលការណ៍នីត្យានុកូលភាព (principle of legality) ដែលក្នុងនោះមានធាតុផ្សំ៖ការអាចដឹងជាមុនបាន ( foreseeability)។ ចៅក្រមបានយោងដល់ឯកសារសិទ្ធិមនុស្សជាច្រើន ដែលចែងហាម

ឃាត់នូវការបំពានសិទ្ធិ និងធ្វើទុក្ខបុកម្នេញ ហើយសន្និដ្ឋានថា ជនល្មើសពិតជាដឹងថា ការសម្លាប់មនុស្ស ដូចជាទាហាន ជាបទឧក្រិដ្ឋ និងនាំឲ្យមានការទទួលខុសត្រូវព្រហ្មទណ្ឌ (កថាខ័ណ្ឌទី៤៤)។ ជាចុងក្រោយ ចៅក្រម អះអាងថា ការបកស្រាយនេះ មិនមានអ្វីផ្ទុយនឹងការអនុវត្តជាក់លាក់របស់រដ្ឋឡើយ (កថាខ័ណ្ឌទី៦៣)។

**<u>កំណត់សំគាល់</u>**៖ <u>១</u>. បទឧក្រិដ្ឋកម្មសង្គ្រាម ការពារទាហាននៃប្រទេសសត្រូវ ដែលក្លាយជាឈ្លើយសឹក (prisoners of war) មិនការពារទាហាននៃប្រទេសរបស់ពួកគេទេ។ ចៅក្រម បានបកស្រាយទូលាយ តាមគោលបំណងនៃបទឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ដើម្បីបំពេញចន្លោះខ្វះខាត សម្រាប់ការពារទាហាន តាមរយៈការដាក់ការវាយប្រហារលើពួកគេ ក្នុងប្រភេទការវាយប្រហារលើជនស៊ីវិល។ អ្វីដែលគួរឲ្យកត់សំគាល់ តាមយុត្តិសាស្ត្រ ប្រសិនបើក្នុង ចំណោមជនស៊ីវិល ដ៏ច្រើនលើសលុប មានទាហានមួយចំនួនតូច ក៏ចាត់ទុកថាជាជនស៊ីវិល ហើយការបកស្រាយថា នរណាជាជនស៊ីវិល ទទួលបានការការពារ (protected person) មិនមែនផ្តោតសំខាន់លើកត្តាសញ្ជាតិទេ (Nationality)។ យុត្តិសាស្ត្របានផ្តោតលើចំណងទាក់ទង (genius link or allegiance)។ ជនស៊ីវិល មានសញ្ជាតិប្រទេស *ក* អាច ធ្វើការងារប្រឆាំងនឹង *ក* ដោយគាំទ្រប្រទេស *ខ* ដែលជាប្រទេសដើមកំណើត។ <u>២.</u>សហចៅក្រម ផ្អែកតាមវិធានទី ៣៣ នៃវិធានផ្ទៃក្នុងរបស់ អវតក បានស្នើសុំឲ្យមាន amicus curiae (យោបល់) ពីបុគ្គល ឬស្ថាប័នក្រៅតុលាការ (មិត្តរបស់តុលាការ) ដើម្បីជួយបំភ្លឺបញ្ហាច្បាប់ចោទនេះ។ មូលដ្ឋាន នៃការស្នើសុំមានពីរះដោយសារបញ្ហាស្មុគ្រស្មាញ និង តុលាការខ្វះធនធាន។ យោបល់នេះ ធ្លាប់បានស្នើសុំ ដោយ ICTY ក្នុងសំណុំរឿង Milosevic ដែលគាត់ការពារក្តីដោយខ្លួនឯង (self-representation)។ ICTY បានចាត់មេធាវីជួយ (standby lawyer) និងសុំយោបល់ជំនួយពីខាងក្រៅផងដែរ។

**<u>Reference and Further Reading</u>**: Sarah William, Hannah Woolaver and Emma Palmer, the Amicus Curiae in International Criminal Justice, 2020; Daryl Mundis, *Amicus Curiae* (p.243), Gillian Higgins, *Slobodan Milosevic* (pp. 811-815) in Antonio Cassese, the Oxford Companion to the International Criminal Justice, 2009.